ក្រសួងពាណិជ្ជកម្ម
លេខ ២២៧ ព.ណ.ក.ក.កមប.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនិងនីតិវិធីនៃការដោះស្រាយតាមការចរចា ក្រោមច្បាប់ស្តីពីការប្រកួតប្រជែង

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១.- គោលបំណង

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការដោះស្រាយតាមការចរចា ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ក្នុងគោលបំណងជំរុញឱ្យមានការដោះស្រាយបទល្មើសឱ្យបានឆាប់រហ័សនិងសមស្រប ធានាឱ្យមានភាពបត់បែន ទទួលបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព និងអាចកាត់បន្ថយបន្ទុកចំណាយនៃការស៊ើបអង្កេត។

### ប្រការ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការដោះស្រាយតាមការចរចា ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ដែលធ្វើឡើងដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ **«ក.ប.ប.»** និងគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា **«គ.ប.ក.»**។

### ប្រការ៣.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាននិយមន័យដូចខាងក្រោម៖

១. **អគ្គនាយកដ្ឋាន ក.ប.ប.** សំដៅដល់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ។

២. **ការលើកទឹកចិត្ត** សំដៅដល់ការកាត់បន្ថយចំនួនទឹកប្រាក់ផាកពិន័យចំពោះបុគ្គលស្ថិតក្រោមការស៊ើបអង្កេតដែលបានចូលរួមធ្វើកិច្ចសហការ និងសម្រេចបាននូវដំណោះស្រាយតាមការចរចា។

៣. **មន្ត្រីស៊ើបអង្កេត** សំដៅដល់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ដែលត្រូវបានចាត់តាំងឱ្យស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

៤. **ការចាប់ផ្តើមនីតិវិធីនៃការស៊ើបអង្កេត** សំដៅដល់ការចាប់ផ្តើមនីតិវិធីនៃការស៊ើបអង្កេតដូចមានចែងក្នុងប្រការ១១នៃប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេតក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

៥. **របាយការណ៍ស៊ើបអង្កេត** សំដៅដល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយមន្ត្រីស៊ើបអង្កេតនៅពេលបិទបញ្ចប់ការស៊ើបអង្កេតជាស្ថាពរ ដូចមានចែងនៅក្នុងប្រការ១៥នៃប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការត្រួតពិនិត្យនិងការស៊ើបអង្កេតក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

៦. **របាយការណ៍ស្តីពីការដោះស្រាយតាមការចរចា** សំដៅដល់របាយការណ៍ជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយមន្ត្រីស៊ើបអង្កេត ដែលជាលទ្ធផលនីតិវិធីនៃការដោះស្រាយតាមការចរចា។

៧. **បុគ្គលស្ថិតក្រោមការស៊ើបអង្កេត** សំដៅដល់បុគ្គលទាំងឡាយណាដែលអាចបំពានច្បាប់ស្តីពីការប្រកួតប្រជែង។

៨. **កិច្ចសន្យាសះជា** សំដៅដល់កិច្ចសន្យាដែលបានបង្កើតឡើង ឬចុះហត្ថលេខាដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលទទួលរងផលប៉ះពាល់ពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងដែលប្រព្រឹត្តដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដែលកិច្ចសន្យានេះ



X

នឹងមានចែងអំពីសំណងនៃការខូចខាត ដែលបុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានព្រមព្រៀងក្នុងការសងសំណងទៅឱ្យបុគ្គលដែលទទួលរងផលប៉ះពាល់។

៩. **លិខិតធានាអះអាង** សំដៅដល់ឯកសារដែលមានចែងអំពីកាតព្វកិច្ច ការធានាអះអាង និងការសន្យារបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតដាក់ជូនមន្ត្រីស៊ើបអង្កេត ដូចមានចែងនៅក្នុងប្រការ១៤នៃប្រកាសនេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច និងការលើកទឹកចិត្ត

### ប្រការ៤.‒ ស្ថាប័នមានសមត្ថកិច្ចក្នុងការដោះស្រាយតាមការចរចា

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** មានសមត្ថកិច្ចដូចខាងក្រោម៖

១. ទទួលពាក្យស្នើសុំដោះស្រាយតាមការចរចា

២. ត្រួតពិនិត្យ តាមដាន ធ្វើសេចក្តីសន្និដ្ឋាន និងវាយតម្លៃលើពាក្យស្នើសុំដោះស្រាយតាមការចរចា

៣. សិក្សាអំពីសំណើ និងធ្វើសេចក្តីសន្និដ្ឋាន ពាក់ព័ន្ធនឹងពាក្យស្នើសុំដោះស្រាយតាមការចរចា និងអនុវត្តនីតិវិធីនៃការដោះស្រាយតាមការចរចា។

### ប្រការ៥.‒ ការលើកទឹកចិត្ត

**គ.ប.ក.** អាចសម្រេចកាត់បន្ថយការផាកពិន័យជាប្រាក់លើបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដែលបានចូលរួមសហការ និងសម្រេចបាននូវការដោះស្រាយតាមការចរចា។ ការលើកទឹកចិត្តអាចត្រូវបានធ្វើឡើងតាមរយៈការកាត់បន្ថយទឹកប្រាក់ផាកពិន័យក្នុងបរិមាណឬទំហំដូចខាងក្រោម៖

១. រហូតដល់ ២៥% នៃប្រាក់ដែលត្រូវផាកពិន័យ ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតស្ម័គ្រចិត្តសារភាពអំពីការបំពានកំឡុងពេលត្រួតពិនិត្យបឋម មុនពេលឬក្នុងកំឡុងពេលស៊ើបអង្កេត ឬមុនពេលមន្ត្រីស៊ើបអង្កេតបញ្ជូនរបាយការណ៍ស្តីពីការស៊ើបអង្កេតជូនគណៈកម្មការលើកលើកណ្តើ ... 

២. រហូតដល់ ១៥% នៃប្រាក់ដែលត្រូវផាកពិន័យ ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតស្ម័គ្រចិត្តសារភាពអំពីការបំពាន មុនពេលគណៈកម្មការលើករណីប្រកួតប្រជែងធ្វើរបាយការណ៍ស្តីពីលទ្ធផលពិនិត្យ និងស្រាវជ្រាវជូន **គ.ប.ក.**។

## ជំពូកទី៣
## ការស្នើសុំ និងសេចក្តីសម្រេចស្តីពីការដោះស្រាយតាមការចរចា

### ប្រការ៦.‒ ព័ត៌មានស្តីពីជម្រើសក្នុងការស្នើសុំដោះស្រាយតាមការចរចា

ក្នុងកំឡុងពេលនីតិវិធីនៃការត្រួតពិនិត្យបឋម ឬនីតិវិធីនៃការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតអាចជូនដំណឹងដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត អំពីជម្រើសក្នុងការស្នើសុំដោះស្រាយតាមការចរចាដូចមានចែងក្នុងមាត្រា២៥នៃច្បាប់ស្តីពីការប្រកួតប្រជែង។

### ប្រការ៧.‒ ពាក្យស្នើសុំដោះស្រាយតាមការចរចា

ទោះជាមិនមានការជូនដំណឹងអំពីជម្រើសក្នុងការស្នើសុំដោះស្រាយតាមការចរចាដោយមន្ត្រីស៊ើបអង្កេត

ក៏ដោយ បុគ្គលស្ថិតក្រោមការស៊ើបអង្កេតអាចដាក់ពាក្យស្នើសុំដោះស្រាយតាមការចរចាទៅកាន់អគ្គនាយកដ្ឋាន **ក.ប.ប.** មុនពេលដែលរបាយការណ៍ស្តីពីការត្រួតពិនិត្យបឋម ឬរបាយការណ៍ស្តីពីលទ្ធផលពិនិត្យនិងស្រាវជ្រាវត្រូវបានបញ្ជូនទៅ **គ.ប.ក.** ដើម្បីចេញសេចក្តីសម្រេច។

ពាក្យស្នើសុំដោះស្រាយតាមការចរចាត្រូវធ្វើឡើងក្នុងទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ ឬត្រូវបានកំណត់ផ្សេងទៀតដោយ **គ.ប.ក.** និងត្រូវចុះហត្ថលេខាដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬអ្នកតំណាងស្របច្បាប់។

ការដាក់ពាក្យស្នើសុំដោះស្រាយតាមការចរចាមិនបង្កើតជាសច្ចធារណ៍ថា បុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានប្រព្រឹត្តបទល្មើសដូចការសង្ស័យនោះទេ។ ការដាក់ពាក្យស្នើសុំនេះមិនអាចឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេតរួចផុតពីការទទួលខុសត្រូវ ចំពោះការព្រមព្រៀងឬសកម្មភាពដែលខ្លួនអាចនឹងចោទ ឬត្រូវបានរកឃើញក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចា ឬនីតិវិធីនៃការស៊ើបអង្កេតនោះទេ។

**ប្រការ៨.- លក្ខខណ្ឌមិនអនុញ្ញាតចំពោះការស្នើសុំដោះស្រាយតាមការចរចា**

ការស្នើសុំដោះស្រាយតាមការចរចាអាចត្រូវបានបដិសេធ ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

១. បទល្មើសដែលត្រូវបានសង្ស័យពាក់ព័ន្ធនឹងការបំពាន ឬអាចបំពានមាត្រា៧នៃច្បាប់ស្តីពីការប្រកួតប្រជែង

២. បុគ្គលស្ថិតក្រោមការស៊ើបអង្កេតមានប្រវត្តិក្នុងការបំពានមាត្រា៧ មាត្រា៨ មាត្រា៩ និងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង ក្នុងកំឡុងពេល៣(បី)ឆ្នាំ គិតមកត្រឹមកាលបរិច្ឆេទនៃការស្នើសុំដោះស្រាយតាមការចរចា

៣. បុគ្គលស្ថិតក្រោមការស៊ើបអង្កេតមានប្រវត្តិមិនអនុវត្តតាមសេចក្តីសម្រេចមុនៗរបស់ **គ.ប.ក.**

៤. សំណុំរឿងដែលកំពុងធ្វើការស៊ើបអង្កេតនេះ អាចឈានទៅដល់ករណីព្រហ្មទណ្ឌ ឬ

៥. បទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ប.ក.** ដោយមានមូលហេតុសមស្រប។

**ប្រការ៩.- សេចក្តីសម្រេចលើពាក្យស្នើសុំដោះស្រាយតាមការចរចា**

នៅពេលទទួលបានពាក្យស្នើសុំដោះស្រាយតាមការចរចា មន្ត្រីស៊ើបអង្កេតត្រូវសិក្សាអំពីសំណើ និងធ្វើសេចក្តីសន្និដ្ឋានដោយភ្ជាប់ជាមួយនូវសំអាងហេតុ ដូចមានចែងក្នុងប្រការ៨នៃប្រកាសនេះជូនអគ្គនាយកនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ដើម្បីពិចារណាថាអនុញ្ញាត ឬមិនអនុញ្ញាតទទួលយកពាក្យស្នើសុំក្នុងការដោះស្រាយតាមការចរចា។ សេចក្តីសន្និដ្ឋានលើពាក្យស្នើសុំដោះស្រាយតាមការចរចា ត្រូវធ្វើឡើងក្នុងទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

អគ្គនាយកនៃអគ្គនាយកដ្ឋាន **ក.ប.ប.** មានឆន្ទានុសិទ្ធិក្នុងការសម្រេចលើការទទួល ឬមិនទទួលយកការស្នើសុំដោះស្រាយតាមការចរចា ដោយធ្វើការពិចារណាលើសេចក្តីសន្និដ្ឋានរបស់មន្ត្រីស៊ើបអង្កេតដែលបានផ្តល់ជូន។

សេចក្តីសន្និដ្ឋានលើពាក្យស្នើសុំដោះស្រាយតាមការចរចា ត្រូវជូនដំណឹងដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងបុគ្គលពាក់ព័ន្ធ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋាន **ក.ប.ប.** ឬតាមមធ្យោបាយផ្សេងទៀតដែលបានកំណត់ដោយ **គ.ប.ក.**។ សេចក្តីសន្និដ្ឋានលើពាក្យស្នើសុំដោះស្រាយតាមការចរចា ដែលត្រូវផ្សព្វផ្សាយជាសាធារណៈនេះ មិនត្រូវរួមបញ្ចូលនូវព័ត៌មានពាក់ព័ន្ធ ដែលត្រូវបានចាត់ទុកថាជាព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់ស្របតាមច្បាប់ស្តីពីការប្រកួតប្រជែង។

## ជំពូកទី៤
## នីតិវិធីនៃការដោះស្រាយតាមការចរចា

### ប្រការ១០._ ការអនុវត្តនីតិវិធីនៃការដោះស្រាយតាមការចរចា

បន្ថែមពីលើព័ត៌មានដែលនឹងត្រូវបង្ហាញដល់បុគ្គលស្ថិតនៅក្រោមការស៊ើបអង្កេត ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ ក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចា មន្ត្រីស៊ើបអង្កេតអាចពិភាក្សាជាមួយបុគ្គលស្ថិតក្រោមការស៊ើបអង្កេតអំពីបញ្ហាដូចខាងក្រោម៖

១. ការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង ដែលបំពានច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិផ្សេងៗ

២. ព័ត៌មានលម្អិតជាក់លាក់នៃសកម្មភាពកែតម្រូវ ដែលតម្រូវឱ្យធ្វើឡើងដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬក្រុមហ៊ុន ឬធុរកិច្ចរបស់បុគ្គលនោះ ដើម្បីទូទាត់សំណងខូចខាតដែលកើតឡើងពីសកម្មភាពដែលបានបំពាន

៣. ព័ត៌មានលម្អិតអំពីសំណង ដែលជាការទូទាត់សំណង ឬការសងសំណងជូនដល់បុគ្គលដែលទទួលរងផលប៉ះពាល់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលសមស្រប រួមមានយន្តការក្នុងការកំណត់និងការត្រួតពិនិត្យលើលទ្ធផល និង

៤. សកម្មភាពនៅពេលអនាគតរបស់បុគ្គលស្ថិតនៅក្រោមការស៊ើបអង្កេត ក្នុងការទប់ស្កាត់ការបំពានសារជាថ្មីឡើងវិញម្តងទៀត ឬការបំពានផ្សេងទៀតក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ដោយរួមបញ្ចូលទាំងរយៈពេល និងព័ត៌មានលម្អិតផ្សេងទៀត។

នៅគ្រប់ដំណាក់កាល មន្ត្រីស៊ើបអង្កេតត្រូវធានាឱ្យបាននូវតម្លាភាព គណនេយ្យភាព និងសុចរិតភាពក្នុងការអនុវត្តនីតិវិធីនៃការដោះស្រាយតាមការចរចា។

### ប្រការ១១._ ព័ត៌មានដែលត្រូវបង្ហាញដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត

ក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចា មន្ត្រីស៊ើបអង្កេតត្រូវបង្ហាញព័ត៌មានដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតដូចខាងក្រោម៖

១. អង្គហេតុដែលចោទប្រកាន់លើបុគ្គលស្ថិតក្រោមការស៊ើបអង្កេត

២. ស្ថានទម្ងន់ទោស និងរយៈពេលនៃការរំលោភបំពាន

៣. ការកំណត់នៃការទទួលខុសត្រូវ

៤. ភស្តុតាង និងឯកសារសំណុំរឿងដែលមិនមានលក្ខណៈជាការសម្ងាត់ តាមការស្នើសុំរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត

៥. ការប៉ាន់ស្មាននៃការផាកពិន័យជាប្រាក់ដែលអាចកើតមានឡើង ដែលសម្រេចដោយ **គ.ប.ក.**។

### ប្រការ១២._ ការរាយការណ៍ និងបញ្ជូនកិច្ចសន្យាសះជា

ក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចា ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានចុះកិច្ចសន្យាសះជាជាមួយបុគ្គលណាមួយ ដែលទទួលឬអាចទទួលរងផលប៉ះពាល់ពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនោះ ត្រូវរាយការណ៍នូវព័ត៌មាននិងកិច្ចសន្យានោះជូនដល់មន្ត្រីស៊ើបអង្កេត។



X

កិច្ចសន្យាសះជានេះអាចត្រូវបានប្រើប្រាស់ដោយ **គ.ប.ក.** ដើម្បីកំណត់អំពីទំហំនៃប្រាក់ផាកពិន័យសរុប និងសំណងសមស្រប សម្រាប់ផ្តល់ជូនបុគ្គលដែលទទួលរងផលប៉ះពាល់ ដោយសារការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត។

## ប្រការ១៣.- កិច្ចប្រជុំ និងការទំនាក់ទំនងក្នុងការចរចា

ការដោះស្រាយតាមការចរចា អាចត្រូវបានធ្វើឡើងតាមរយៈកិច្ចប្រជុំ ឬការទំនាក់ទំនងជាលាយលក្ខណ៍អក្សររវាងមន្ត្រីស៊ើបអង្កេត បុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលដែលទទួលរងផលប៉ះពាល់ពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

ការទំនាក់ទំនងជាលាយលក្ខណ៍អក្សរត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬលិខិតជាលាយលក្ខណ៍អក្សរផ្ញើតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមមធ្យោបាយផ្សេងទៀតដែលបានព្រមព្រៀងគ្នាជាមុនដោយមន្ត្រីស៊ើបអង្កេត បុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងបុគ្គលដែលទទួលរងផលប៉ះពាល់ពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង។

កិច្ចប្រជុំត្រូវផ្តើមធ្វើឡើងដោយមន្ត្រីស៊ើបអង្កេត ឬបុគ្គលស្ថិតក្រោមការស៊ើបអង្កេត។ ការជូនដំណឹងអំពីកិច្ចប្រជុំត្រូវភ្ជាប់ជាមួយរបៀបវារៈនិងឯកសារពាក់ព័ន្ធ ជូនគ្រប់ភាគីទាំងអស់យ៉ាងតិចក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំ។ មន្ត្រីស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុនៃកិច្ចប្រជុំ ដែលកំណត់ហេតុនេះត្រូវមានហត្ថលេខារបស់អ្នកចូលរួមក្នុងកិច្ចប្រជុំទាំងអស់។

ក្នុងករណីមានអ្នកចូលរួមក្នុងកិច្ចប្រជុំបដិសេធមិនព្រមចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំ ដែលបានតម្រូវនៅក្នុងប្រការនេះ មន្ត្រីស៊ើបអង្កេតត្រូវចុះនិទ្ទេសអំពីការបដិសេធ ព្រមទាំងមូលហេតុអំពីការបដិសេធនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះ។

កិច្ចប្រជុំអាចពន្យារពេលទៅកាលបរិច្ឆេទផ្សេងទៀត មិនលើសពី៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលកំណត់លើកមុន ប្រសិនបើមានការស្នើសុំពីមន្ត្រីស៊ើបអង្កេត ឬបុគ្គលស្ថិតក្រោមការស៊ើបអង្កេត។

ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតអវត្តមានក្នុងកិច្ចប្រជុំចំនួន២(ពីរ)ដងជាប់ៗគ្នាដោយមិនមានមូលហេតុសមស្រប នីតិវិធីនៃការដោះស្រាយតាមការចរចានឹងត្រូវបិទបញ្ចប់ ដោយចាត់ទុកថានីតិវិធីនៃការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យដូចមានចែងក្នុងប្រការ១៧នៃប្រកាសនេះ។ មន្ត្រីស៊ើបអង្កេតត្រូវធ្វើរបាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យ នៅក្នុងទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៦នៃប្រកាសនេះ ដើម្បីដាក់ជូន **គ.ប.ក.** ហើយនីតិវិធីនៃការត្រួតពិនិត្យបឋមនិងស៊ើបអង្កេតត្រូវចាប់ផ្តើមឬបន្តឡើងវិញ។

កិច្ចប្រជុំ ឬការទំនាក់ទំនងនៃការចរចាត្រូវបិទបញ្ចប់ក្នុងរយៈពេលមិនលើស១២០(មួយរយម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំនៃការចរចាលើកដំបូង ឬទំនាក់ទំនងជាលាយលក្ខណ៍អក្សរនៃការចរចាលើកដំបូង។

## ប្រការ១៤.- ការដាក់លិខិតធានាអះអាង

នៅពេលបញ្ចប់កិច្ចប្រជុំនៃការចរចា ឬការទំនាក់ទំនងនៃការចរចា បុគ្គលស្ថិតក្រោមការស៊ើបអង្កេតមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីដាក់លិខិតធានាអះអាងរបស់ខ្លួនជូន **គ.ប.ក.**។

លិខិតជានាអះអាងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្នុងទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ ឬត្រូវបានកំណត់ផ្សេងទៀតដោយ **គ.ប.ក.** និងត្រូវចុះហត្ថលេខាដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬអ្នកតំណាងស្របច្បាប់ ដោយត្រូវបញ្ជាក់ព័ត៌មានដូចខាងក្រោម៖

១. ការទទួលស្គាល់ ឬការសារភាពរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតអំពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

២. ការព្រមព្រៀងក្នុងការបញ្ឈប់ និងមិនប្រព្រឹត្តសារជាថ្មីម្តងទៀត នូវការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

៣. ព័ត៌មានលម្អិតជាក់លាក់អំពីសកម្មភាពកែតម្រូវ ដែលធ្វើឡើងដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិង/ឬធុរកិច្ចរបស់បុគ្គលនោះ ដើម្បីធ្វើការទូទាត់សំណងខូចខាតដែលកើតឡើងពីការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងនោះ

៤. ព័ត៌មានលម្អិតអំពីសំណង ដែលជាការទូទាត់សំណង ឬការសងសំណងជូនដល់បុគ្គលដែលទទួលរងផលប៉ះពាល់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលសមស្រប រួមមានយន្តការក្នុងការកំណត់និងការត្រួតពិនិត្យលើលទ្ធផល

៥. វិធានការផ្សេងៗទៀត ដោយអនុលោមតាមមាត្រា៣៧នៃច្បាប់ស្តីពីការប្រកួតប្រជែង

៦. សកម្មភាពនៅពេលអនាគតរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត និង/ឬធុរកិច្ចរបស់បុគ្គលនោះក្នុងការទប់ស្កាត់ការបំពានសារជាថ្មីឡើងវិញម្តងទៀត ឬការបំពានផ្សេងទៀតនៃច្បាប់ស្តីពីការប្រកួតប្រជែង (ដូចជាការអនុលោមផ្ទៃក្នុងតាមគោលការណ៍ណែនាំ និង/ឬកម្មវិធីតម្រង់ទិស) ដោយរួមបញ្ចូលទាំងរយៈពេលនិងព័ត៌មានលម្អិតផ្សេងទៀត

៧. ការតម្រូវក្នុងការរាយការណ៍ពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតជូន **គ.ប.ក.** ដោយអាចរួមបញ្ចូលដូចខាងក្រោម៖

   ក. របាយការណ៍នៅពេលដែលបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និង/ឬធុរកិច្ចរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត បានអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងលិខិតជានាអះអាង និង

   ខ. ការផ្តល់ព័ត៌មាន និងឯកសារយោងពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតជូន **គ.ប.ក.** ដើម្បីបញ្ជាក់ថាខ្លួនបានអនុវត្តកាតព្វកិច្ចនៅក្នុងលិខិតជានាអះអាង

៨. ការយល់ព្រម និងទទួលស្គាល់ថា លិខិតជានាអះអាងត្រូវផ្សព្វផ្សាយជាសាធារណៈ។

លិខិតជានាអះអាងមិនត្រូវរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

១. ការបដិសេធទៅលើការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

២. លក្ខខណ្ឌណាមួយដែលដាក់កាតព្វកិច្ចលើតតិយជន

៣. លក្ខខណ្ឌណាមួយ ដែលមានចេតនាគេចវេះពីការទទួលខុសត្រូវផ្សេងទៀត

៤. លក្ខខណ្ឌដែលតម្រូវឱ្យមន្ត្រីស៊ើបអង្កេត ឬ **គ.ប.ក.** មិនអាចចាប់ផ្តើមដំណើរការនីតិវិធីច្បាប់ចំពោះបុគ្គលស្ថិតក្រោមការស៊ើបអង្កេតនៅពេលអនាគត។

លិខិតជានាអះអាងរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត មិនអាចត្រូវបានយកមកប្រើជាភស្តុតាង ឬជាការសំអាងនៅក្នុងនីតិវិធីស៊ើបអង្កេត ក្នុងករណីដែលនីតិវិធីនៃការដោះស្រាយតាមការចរចាមិនទទួលបានជោគជ័យនោះទេ។

**ប្រការ១៥._ ការត្រួតពិនិត្យបឋមរបស់មន្ត្រីស៊ើបអង្កេតលើលិខិតធានាអះអាង**

ក្នុងកំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានដាក់លិខិតធានាអះអាង មន្ត្រីស៊ើបអង្កេតត្រូវពិនិត្យលិខិតធានាអះអាងនោះ ដើម្បីបញ្ជាក់នូវចំណុចដូចខាងក្រោម៖

១. ភាពសមស្របនៃលិខិតធានាអះអាង ផ្អែកតាមទម្រង់និងលក្ខខណ្ឌតម្រូវសំខាន់ៗដូចមានចែងនៅក្នុងប្រការ១៤នៃប្រកាសនេះ និង

២. លិខិតធានាអះអាងបានបញ្ជាក់ពីខសន្យានិងលក្ខខណ្ឌដែលបានពិភាក្សា និងព្រមព្រៀងគ្នានៅក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចា។

មន្ត្រីស៊ើបអង្កេតត្រូវរៀបចំរបាយការណ៍អំពីការត្រួតពិនិត្យបឋមលើលិខិតធានាអះអាង ក្នុងទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

ប្រសិនបើមន្ត្រីស៊ើបអង្កេតរកឃើញថា លិខិតធានាអះអាងនេះមិនបានធ្វើឡើងដោយអនុលោមតាមប្រការ១៤ និងប្រការ១៥នៃប្រកាសនេះ មន្ត្រីស៊ើបអង្កេតត្រូវផ្តល់ព័ត៌មានទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេតអំពីបញ្ហានេះ និងធ្វើការណែនាំឱ្យកែតម្រូវលើលិខិតធានាអះអាងនេះ។

ក្រោយពីទទួលបានសេចក្តីជូនដំណឹងពីមន្ត្រីស៊ើបអង្កេត បុគ្គលស្ថិតក្រោមការស៊ើបអង្កេតមានរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការកែតម្រូវនិងដាក់លិខិតធានាអះអាងម្តងទៀត។ មន្ត្រីស៊ើបអង្កេតអាចសម្រេចពន្យារពេលបន្ថែមមិនឱ្យលើសពី៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ តាមការស្នើសុំរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតដោយផ្អែកលើមូលហេតុសមស្រប។

ប្រសិនបើមន្ត្រីស៊ើបអង្កេតមិនបានទទួលលិខិតធានាអះអាងដែលកែតម្រូវរួច ក្នុងកំឡុងពេលដែលបានកំណត់នោះ នីតិវិធីនៃការដោះស្រាយតាមការចរចាត្រូវចាត់ទុកថាមិនទទួលបានជោគជ័យដូចមានចែងក្នុងប្រការ១៧នៃប្រកាសនេះ។ មន្ត្រីស៊ើបអង្កេតត្រូវធ្វើរបាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យជូន **គ.ប.ក.** ដោយប្រើប្រាស់ទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៦នៃប្រកាសនេះ ហើយនីតិវិធីនៃការត្រួតពិនិត្យបឋមឬស៊ើបអង្កេតត្រូវចាប់ផ្តើម ឬបន្តឡើងវិញ។

**ប្រការ១៦._ ការបញ្ចប់នីតិវិធីនៃការដោះស្រាយតាមការចរចា**

នីតិវិធីនៃការដោះស្រាយតាមការចរចាត្រូវបានបិទបញ្ចប់ ទោះបីជាការដោះស្រាយតាមការចរចានោះទទួលបានជោគជ័យ ឬមិនទទួលបានជោគជ័យក៏ដោយ។

នៅពេលបិទបញ្ចប់នីតិវិធីនៃការដោះស្រាយតាមការចរចា មន្ត្រីស៊ើបអង្កេតត្រូវ៖

១. ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេត អំពីការបិទបញ្ចប់នីតិវិធីនៃការដោះស្រាយតាមការចរចាដោយប្រើប្រាស់ទម្រង់ ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

២. រៀបចំនូវរបាយការណ៍ ដោយប្រើប្រាស់ទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៦នៃប្រកាសនេះ ក្នុងករណីការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យ។

៣. រៀបចំនូវរបាយការណ៍ ដោយប្រើប្រាស់ទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៧នៃប្រកាសនេះ ក្នុងករណីការដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ។

## ប្រការ១៧.- ការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យ

ការដោះស្រាយតាមការចរចាត្រូវចាត់ទុកថា មិនទទួលបានជោគជ័យ ក្នុងករណីដូចខាងក្រោម៖

១. បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនិងមន្ត្រីស៊ើបអង្កេតមិនអាចស្វែងរកដំណោះស្រាយទៅលើសំណុំរឿងក្នុងកំឡុងពេលនៃកិច្ចប្រជុំ និងការទំនាក់ទំនងនៃការចរចា តាមរយៈពេលកំណត់ដូចមានចែងក្នុងប្រការ១៣នៃប្រកាសនេះ។

២. មន្ត្រីស៊ើបអង្កេតមិនបានទទួលលិខិតជានាអះអាង ឬការកែតម្រូវលើលិខិតជានាអះអាង ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងប្រការ១៤ និងប្រការ១៥នៃប្រកាសនេះ ឬ

៣. មូលហេតុផ្សេងទៀតដែលត្រូវបានកំណត់ដោយឆន្ទានុសិទ្ធិរបស់ **គ.ប.ក.**។

## ប្រការ១៨.- ការដាក់របាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យជូន គ.ប.ក.

របាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យ ត្រូវមានព័ត៌មានដូចខាងក្រោម៖

១. ការសង្ខេបអំពីអង្គហេតុ

២. ការរំលោភបំពានដែលត្រូវបានចោទប្រកាន់ និងការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

៣. ការសង្ខេបអំពីនីតិវិធីនៃការដោះស្រាយតាមការចរចា

៤. មូលហេតុដែលមិនទទួលបានជោគជ័យក្នុងការដោះស្រាយតាមការចរចា និង

៥. ព័ត៌មានពាក់ព័ន្ធនឹងនីតិវិធីបន្ទាប់ រួមបញ្ចូលទាំងនីតិវិធីនៃការត្រួតពិនិត្យបឋមឬស៊ើបអង្កេត។

## ប្រការ១៩.- ការដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ

ការដោះស្រាយតាមការចរចាអាចចាត់ទុកថា ទទួលបានជោគជ័យ គឺនៅពេលដែលបុគ្គលស្ថិតក្រោមការស៊ើបអង្កេតបានដាក់លិខិតជានាអះអាងជូនមន្ត្រីស៊ើបអង្កេតដោយអនុលោមតាមប្រការ១៤ និងប្រការ១៥នៃប្រកាសនេះ ហើយមន្ត្រីស៊ើបអង្កេតធ្វើការត្រួតពិនិត្យនិងវាយតម្លៃបឋម និងដាក់ជូន **គ.ប.ក.** ដើម្បីពិនិត្យនិងសម្រេចចុងក្រោយ ដោយភ្ជាប់ជាមួយរបាយការណ៍ស្តីពីការដោះស្រាយតាមការចរចានេះ។

## ប្រការ២០.- ការដាក់របាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ

របាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ ត្រូវកំណត់ព័ត៌មានដូចខាងក្រោម៖

១. ឯកសារភ្ជាប់នៃលិខិតជានាអះអាង ដែលបានដាក់ដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត និងសេចក្តីណែនាំរបស់មន្ត្រីស៊ើបអង្កេតស្តីពីលិខិតជានាអះអាងនោះ

២. សេចក្តីសន្និដ្ឋានរបស់មន្ត្រីស៊ើបអង្កេតស្តីពីចំនួនទឹកប្រាក់ដែលត្រូវផាកពិន័យ និងវិធានការផ្សេងទៀត ដូចមានចែងក្នុងមាត្រា៣៥ និងមាត្រា៣៧នៃច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីដាក់ពិន័យលើបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកតាមលក្ខណៈនៃការព្រមព្រៀងឬសកម្មភាពដែលអាចរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង

៣. សេចក្តីសន្និដ្ឋានរបស់មន្ត្រីស៊ើបអង្កេតស្តីពីការលើកទឹកចិត្ត ដល់បុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត ត្រូវភ្ជាប់ជាមួយមូលហេតុបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋាននោះ

៤. ការស្នើសុំរបស់មន្ត្រីស៊ើបអង្កេត ដើម្បីឱ្យ **គ.ប.ក.** សម្រេចលើបញ្ហានោះ និង

៥. ព័ត៌មានសំខាន់ៗផ្សេងទៀត ដែលពាក់ព័ន្ធនឹងនីតិវិធីនៃការដោះស្រាយតាមការចរចា និងការគាំទ្រ ទៅលើសេចក្តីសន្និដ្ឋាន និងការស្នើសុំខាងលើ។

ចំពោះការផ្តល់សេចក្តីសន្និដ្ឋានជូន **គ.ប.ក.** ស្តីពីការលើកទឹកចិត្តដែលត្រូវផ្តល់ឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេត មន្ត្រីស៊ើបអង្កេតអាចធ្វើការពិចារណាលើចំណុចដូចខាងក្រោម៖

១. លក្ខណៈនៃការរំលោភបំពានដែលត្រូវបានចោទប្រកាន់

២. លទ្ធភាពក្នុងការផ្តល់សំណងជូនទៅបុគ្គលដែលទទួលរងផលប៉ះពាល់

៣. ភាពសុចរិត និងភាពស្មោះត្រង់ និងប្រវត្តិល្អនៃការអនុវត្តពីមុនរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត

៤. កិច្ចសហការរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេត ក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចា។

## ជំពូកទី៥
## សេចក្តីសម្រេចលើលទ្ធផលស្តីពីការដោះស្រាយតាមការចរចា

### ប្រការ២១.- ឆន្ទានុសិទ្ធិរបស់ គ.ប.ក.

**គ.ប.ក.** មានឆន្ទានុសិទ្ធិពេញលេញក្នុងការធ្វើសេចក្តីសម្រេចលើសំណុំរឿង ដោយធ្វើការពិចារណាលើរបាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ។ សេចក្តីសម្រេចស្តីពីការដោះស្រាយតាមការចរចារបស់ **គ.ប.ក.** ត្រូវធ្វើឡើងនៅក្នុងទម្រង់ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៨នៃប្រកាសនេះ ហើយមានអានុភាពចងកាតព្វកិច្ច និងអានុភាពគតិយុត្ត។

**គ.ប.ក.** អាចចេញសេចក្តីសម្រេចទទួលស្គាល់ ឬបដិសេធទាំងមូល ឬដោយផ្នែកនៃរបាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ។ **គ.ប.ក.** ក៏អាចតម្រូវឱ្យមន្ត្រីស៊ើបអង្កេតអនុវត្តនីតិវិធីនៃការដោះស្រាយតាមការចរចាឡើងវិញ ជាមួយនឹងបុគ្គលស្ថិតក្រោមការស៊ើបអង្កេតទាក់ទងនឹងលក្ខខណ្ឌរបស់ **គ.ប.ក.**។

នីតិវិធីរបស់ **គ.ប.ក.** ក្នុងការបើកកិច្ចប្រជុំ ដើម្បីពិភាក្សានិងធ្វើសេចក្តីសម្រេច ត្រូវធ្វើឡើងដោយអនុលោមតាមប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចរបស់ **គ.ប.ក.** និងបទបញ្ជាផ្ទៃក្នុងស្តីពីរបៀបរបបការងាររបស់ **គ.ប.ក.**។

### ប្រការ២២.- ការធ្វើការដោះស្រាយតាមការចរចាឡើងវិញ

ក្នុងកំឡុងពេលនីតិវិធីនៃការដោះស្រាយតាមការចរចាឡើងវិញ មន្ត្រីស៊ើបអង្កេតត្រូវជូនដំណឹងទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេតអំពីលក្ខខណ្ឌដែលបានកំណត់ដោយ **គ.ប.ក.** ទាក់ទងនឹងលិខិតធានាអះអាង។

បុគ្គលស្ថិតក្រោមការស៊ើបអង្កេតមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ក្នុងការពិចារណាអំពីលក្ខខណ្ឌដែលបានកំណត់ដោយ **គ.ប.ក.** ហើយធ្វើការកែតម្រូវនិងដាក់លិខិតធានាអះអាងរបស់ខ្លួនសារជាថ្មីឡើងវិញ។ រយៈពេលនេះអាចធ្វើការពន្យារពេលបាន១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ថែមទៀត ផ្អែកតាមការសម្រេចរបស់មន្ត្រីស៊ើបអង្កេត តាមការស្នើសុំរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតដោយមានមូលហេតុសមស្រប។

ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតព្រមទទួលយកលក្ខខណ្ឌដែលបានកំណត់ដោយ **គ.ប.ក.** បុគ្គលស្ថិតក្រោមការស៊ើបអង្កេតត្រូវធ្វើការកែតម្រូវលិខិតធានាអះអាងរបស់ខ្លួន និងត្រូវដាក់លិខិតធានាអះអាងនេះម្តងទៀតជូនមន្ត្រីស៊ើបអង្កេតក្នុងរយៈពេលកំណត់។ នៅពេលទទួលបានលិខិតធានាអះអាងដែលបានកែតម្រូវរួចរាល់

មន្ត្រីស៊ើបអង្កេតត្រូវដាក់របាយការណ៍ស្តីពីការដោះស្រាយតាមការចរចា ដែលទទួលបានជោគជ័យមួយទៀតជូន **គ.ប.ក.** ដើម្បីចេញសេចក្តីសម្រេច។

ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតមិនព្រមទទួលយកលក្ខខណ្ឌដែលបានកំណត់ដោយ **គ.ប.ក.** ឬមិនបានដាក់លិខិតជានាអះអាងសារជាថ្មីឡើងវិញម្តងទៀតក្នុងរយៈពេលកំណត់ ការដោះស្រាយតាមការចរចាត្រូវបានចាត់ទុកថាជាការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យ។ ក្នុងករណីនេះ មន្ត្រីស៊ើបអង្កេតត្រូវដាក់របាយការណ៍ស្តីពីការដោះស្រាយតាមការចរចាដែលមិនទទួលបានជោគជ័យ ដូចមានចែងក្នុងប្រការ១៨ នៃប្រកាសនេះ។

### ប្រការ២៣.- បណ្តឹងទាមទារឱ្យត្រួតពិនិត្យឡើងវិញ និងបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ គ.ប.ក.

បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ **គ.ប.ក.** អាចប្តឹងតវ៉ាទៅ **គ.ប.ក.** ឱ្យពិនិត្យនិងសម្រេចឡើងវិញចំពោះសេចក្តីសម្រេចទាំងនេះ ឬអាចធ្វើការប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៣០ និងមាត្រា៣១នៃច្បាប់ស្តីពីការប្រកួតប្រជែង។

នីតិវិធីនៃបណ្តឹងតវ៉ាត្រូវធ្វើឡើងដោយអនុលោមតាមប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចរបស់ **គ.ប.ក.** និងបទបញ្ជាផ្ទៃក្នុងស្តីពីរបៀបរបបការងាររបស់ **គ.ប.ក.**។

### ប្រការ២៤.- ការអនុវត្តសេចក្តីសម្រេចរបស់ គ.ប.ក.

អគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវធ្វើការត្រួតពិនិត្យ និងតាមដានការអនុវត្តលក្ខខណ្ឌដែលបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់ **គ.ប.ក.**។

ក្នុងកំឡុងពេលនៃការអនុវត្តសេចក្តីសម្រេច អគ្គនាយកដ្ឋាន **ក.ប.ប.** មានសិទ្ធិក្នុងការស្នើសុំព័ត៌មានបន្ថែមស៊ើបអង្កេត ឬស្រាវជ្រាវអំពីបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដោយផ្អែកលើសកម្មភាពដូចមានចែងនៅក្នុងលក្ខខណ្ឌនៃការដោះស្រាយតាមការចរចានេះ។

### ប្រការ២៥.- ការមិនអនុលោមតាមសេចក្តីសម្រេចដោយបុគ្គលស្ថិតក្រោមការស៊ើបអង្កេត

ក្នុងករណីបុគ្គលស្ថិតក្រោមការស៊ើបអង្កេតមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងសេចក្តីសម្រេចស្តីពីការដោះស្រាយតាមការចរចា **គ.ប.ក.** ត្រូវចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរទៅបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ដើម្បីធ្វើការកែតម្រូវការបំពាននេះ។

ប្រសិនបើបុគ្គលស្ថិតក្រោមការស៊ើបអង្កេតមិនធ្វើការកែតម្រូវការបំពានក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានការជូនដំណឹងអំពីការមិនអនុវត្តកាតព្វកិច្ច **គ.ប.ក.** អាចៈ

១. ចេញវិធានការផ្អាកជាបណ្តោះអាសន្ន ប្រសិនបើមានការតម្រូវស្របតាមមាត្រា២៧នៃច្បាប់ស្តីពីការប្រកួតប្រជែង និង/ឬ

២. ដាក់ពាក្យស្នើសុំឱ្យអនុវត្តសេចក្តីសម្រេចស្តីពីការដោះស្រាយតាមការចរចា ទៅតុលាការមានសមត្ថកិច្ចស្របតាមមាត្រា៣៣នៃច្បាប់ស្តីពីការប្រកួតប្រជែង និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

### ប្រការ២៦._ និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ២៧._ ភារអនុវត្ត

សមាសភាពនៃគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់គ្រងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើតខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបសម្ព័ន្ធទី១**

# ពាក្យស្នើសុំដោះស្រាយតាមការចរចា

**☐ នីតិបុគ្គល**

ក. ឈ្មោះក្រុមហ៊ុន ..........................................................................................

ខ. ព័ត៌មានអំពីការចុះបញ្ជីក្រុមហ៊ុន ..........................................................................................

វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ.............................ចុះថ្ងៃទី ......................

គ. អាសយដ្ឋានក្រុមហ៊ុន ..........................................................................................

ឃ. ព័ត៌មាននៃអ្នកតំណាងក្រុមហ៊ុន

ឈ្មោះ.......................................ភេទ ........ អាយុ........ឆ្នាំ ជនជាតិ ..................សញ្ជាតិ............

លិខិតឆ្លងដែន/អត្តសញ្ញាណបណ្ណលេខ.................................... លេខទូរស័ព្ទ.............................

អ៊ីម៉ែល.................................... តួនាទី/មុខតំណែង.........................................................

**☐ រូបវន្តបុគ្គល**

ឈ្មោះ.................................................. ភេទ......... អាយុ......... ឆ្នាំ ជនជាតិ........... សញ្ជាតិ..............

លិខិតឆ្លងដែន/អត្តសញ្ញាណបណ្ណលេខ.................................. មុខរបរ...................... ទីលំនៅពិតប្រាកដ ផ្ទះលេខ........... ផ្លូវ.................. សង្កាត់/ឃុំ........................ ខណ្ឌ/ស្រុក/ក្រុង....................... រាជធានី/ខេត្ត .................................. លេខទូរស័ព្ទ.................................. អ៊ីម៉ែល..............................................។

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ក.ប.ប.**

**កម្មវត្ថុ** ៖ សំណើសុំដោះស្រាយតាមការចរចាលើសំណុំរឿងលេខ................. ចុះថ្ងៃទី.........................

**យោង** ៖ ..........................................................................................

..........................................................................................

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមស្នើសុំធ្វើការដោះស្រាយតាមការចរចា ដោយមានមូលហេតុដូចខាងក្រោម៖

១. ..........................................................................................

២. ..........................................................................................

៣. ..........................................................................................

ខ្ញុំបាទ/នាងខ្ញុំ សូមទទួលស្គាល់ ជានាអះអាង និងបញ្ជាក់ថាខ្ញុំបាទ/នាងខ្ញុំបានអាន និងយល់អំពីកាតព្វកិច្ចរបស់ខ្ញុំបាទ/នាងខ្ញុំ ព្រមទាំងសិទ្ធិនិងកាតព្វកិច្ច ក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ដូច្នេះ ខ្ញុំបាទ/នាងខ្ញុំទទួលយកនូវរាល់កាតព្វកិច្ចទាំងអស់ នៅក្នុងកិច្ចសហការជាមួយ **គ.ប.ក.** អគ្គនាយកដ្ឋាន **ក.ប.ប.** និងមន្ត្រីស៊ើបអង្កេត នៅពេលការស្នើសុំរបស់ខ្ញុំបាទ/នាងខ្ញុំ បានទទួលការអនុញ្ញាត។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឱ្យខ្ញុំបាទ/នាងខ្ញុំ ចូលរួមក្នុងការដោះស្រាយតាមការចរចានៅក្នុងសំណុំរឿងខាងលើ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.............................ខែ...........ឆ្នាំ....................ព.ស.២៥.....

ធ្វើនៅ............................... ថ្ងៃទី......... ខែ......... ឆ្នាំ២០.......

**ហត្ថលេខា/ស្នាមមេដៃ**

.........................................

[ឈ្មោះអ្នកដាក់ពាក្យស្នើសុំ]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបសម្ព័ន្ធទី២**

សំណុំរឿងលេខ:..................................

## សេចក្តីសន្និដ្ឋានលើ
